កងយោធពលខេមរភូមិន្ទ កងកំលាំងសន្តិសុខជាតិ កងជីវពល អាជ្ញាធរមូលដ្ឋាន ត្រូវរួមសហការពង្រីកផ្ទង់ការពារ ដើម្បីប្រជាកសិករ មានលទ្ធភាពពង្រីកផ្ទៃដាំដុះ និងច្រូតកាត់ប្រមូលផល បានដោយសុវត្ថិភាព ។

គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ ខេត្ត-ក្រុង និងអង្គភាពពាក់ពន្ធ័ ត្រូវសហការគ្នាអោយជិតស្និទ្ធអនុវត្តខ្លឹមសារសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់ អោយសមស្របទៅតាមមូលដ្ឋាននីមួយ ៗ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្ថលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤*

## សារាចរលេខ ០៩ សរច
## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃយន្តការ « ចំណុចប្រមូលផ្តុំ » និង » ច្រកចេញ ចូល តែមួយ » របស់គណៈ កម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ( គ.ជ.នា )

យោងតាមមាត្រាទី ៣ មាត្រាទី៤ និងមាត្រាទី៥ ជំពូកទី២ នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ និងនៅក្នុងពេលរង់ចាំការកំណត់ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមអនុក្រឹត្យ និងដើម្បីដំណើរការកិច្ចការនិតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំកិច្ចដំណើរការរបស់យន្តការ " ចំណុចប្រមូលផ្តុំ " និង "ច្រកចេញ ចូលតែមួយ " របស់ គណៈកម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ( គ.ជ.នា ) ដូចខាងក្រោម :

១- យន្តការ " ចំណុចប្រមូលផ្តុំ " :

គណៈកម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ( គ.ជ.នា ) គឺជា " ចំណុចប្រមូលផ្តុំ " ក្នុងរាល់ទំនាក់ទំនងរវាងបណ្តាស្ថាប័នរបស់រាជរដ្ឋាភិបាល និងបណ្តាអង្គការ និងស្ថាប័នផ្តល់ជំនួយទាំងអស់មកដល់ព្រះរាជាណាចក្រកម្ពុជា ។ គ.ជ.នា មានភារកិច្ចផ្តល់ទៅអោយក្រុមបេសកកម្មនៃអង្គការ និងស្ថាប័នផ្តល់ជំនួយទាំងនោះ

នូវពត៌មានសេដ្ឋកិច្ចទូទៅរបស់ ប្រទេស ទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ គ.ជ.នា ត្រូវជូនពត៌មានអំពីយុទ្ធសាស្ត្រ គោលនយោបាយ អាទិភាពសេដ្ឋកិច្ច និងគំរោងការអាទិភាពតាមផ្នែកសេដ្ឋកិច្ចនិមួយៗ ។ គ.ជ.នា ក៏ត្រូវជំរាបនូវបណ្តាស្ថាប័ននានាដែលអាចផ្តល់ពត៌មានលំអិតនិងមានផលប្រយោជន៍បានទៅដល់ក្រុមបេសកកម្មបរទេស ។ នៅពេលបញ្ចប់បេសកកម្ម សាម៉ីស្ថាប័នត្រូវរាយការណ៍លទ្ធផលនៃការពិភាក្សាទៅរាជរដ្ឋាភិបាល ដោយចម្លងជូនទៅ ក.អ.ក ។ ក្នុងករណីចាំបាច់ ក.អ.ក នឹងដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលរវាងក្រុមបេសកកម្មជាមួយបណ្តាស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

រាល់កិច្ចព្រមព្រៀង អនុស្សារណៈ កិរិតជាតិដែលមានវិសាលភាពទូលំទូលាយ ហើយដែលជាមូលដ្ឋានសំរាប់ការចាត់ចែងបន្ត ក្នុងការរៀបចំកិច្ចសំរុះសំរួលផ្សេងៗទៀត ត្រូវមានការឯកភាពលើខ្លឹមសារពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជាមុនហើយស្ថាប័នដែលត្រូវចុះហត្ថលេខាជាមួយភាគីផ្តល់ជំនួយ ចាំបាច់ត្រូវបានទទួលការប្រគល់សិទ្ធិពីរាជរដ្ឋាភិបាល ជា មុនសិន ។

រាល់គំរោងការអាទិភាពរបស់រាជរដ្ឋាភិបាល ដែលសាម៉ីស្ថាប័នមានបំណងស្នើសុំជំនួយ ត្រូវផ្ញើមក ក.អ.ក ដើម្បីពិនិត្យមានយោបល់ជាមុន ហើយក្នុងករណីឯកភាព ក.អ.ក នឹងបញ្ជូនទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដើម្បីរៀបចំសំណើផ្លូវទូតទៅបណ្តាអង្គការ ស្ថាប័ន និងប្រទេសផ្តល់ជំនួយទាំងអស់នោះ ។

ដើម្បីសំរួលដល់ការទំនាក់ទំនងការងារ និងការផ្លាស់ប្តូរផ្តល់ពត៌មានរវាងបណ្តាស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល ស្ថាប័ននីមួយៗត្រូវរៀបចំ ផ្នែកមួយអោយទទួលបន្ទុកការងារគ្រប់គ្រងកម្មវិធី និងជំនួយ បរទេសក្នុងផ្នែកដែលខ្លួន ទទួលខុសត្រូវ ។

បណ្តាស្ថាប័នដែលអនុវត្តកម្មវិធី និងគំរោងការជំនួយបរទេស ត្រូវរាយការណ៍តាមការកំណត់ទៀងទាត់ ( ៦ខែ និងប្រចាំឆ្នាំ ) មករាជរដ្ឋាភិបាល និងចំលងជូន ក.អ.ក ដើម្បីអោយស្ថាប័នទាំងពីរនេះក្តាប់បានយ៉ាងណែននូវការរីកចំរើន ក្នុងការអនុវត្តន៍កម្មវិធី និងគំរោងការទាំងនេះ និងមានវិធានការដោះស្រាយបានទាន់ពេលវេលានូវបណ្តាការលំបាកទាំងឡាយ ដែលអាចកើតឡើងជាយថាហេតុ ។

ក.អ.ក ត្រូវរៀបចំប្រជុំតាមការកំណត់ទៀងទាត់ ( ៦ខែ និងប្រចាំឆ្នាំ ) ដើម្បីសំរបសំរួលការប្រើប្រាស់ជំនួយអន្តរជាតិ ទៅតាមវិស័យនិមួយៗ និងទៅតាមអង្គការស្ថាប័ន និងប្រទេសផ្តល់ជំនួយនិមួយៗ ។

២- យន្តការ " ច្រកចេញ ចូលតែមួយ " ៖

យន្តការ " ច្រកចេញ ចូលតែមួយ " នៅក្នុងកិច្ចការនិតិសម្បទា និងអភិវឌ្ឍន៍ ត្រូវដំណើរការតាមការរៀបចំដូច ខាងក្រោម ៖

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការត្រូវចាត់មន្ត្រីរបស់ខ្លួន ថ្នាក់ប្រធាន ឬ អនុប្រធាននាយកដ្ឋាន មួយរូបអោយមកអមគណៈកម្មាធិការនិតិ សម្បទា និងអភិវឌ្ឍន៍ ។ មន្ត្រីជាតំណាងរបស់ក្រសួងទាំង ៤ ខាងលើគឺជាតំណាងអចិន្ត្រៃយ៍ប្រចាំ " គ.ជ.នា " ។ គ.ជ.នា ត្រូវរៀបចំបន្ទប់ការិយាល័យមួយសំរាប់ការងាររបស់មន្ត្រីទាំង ៤ រូបខាងលើ ។ មន្ត្រីទាំង ៤ រូបនេះ ត្រូវមានវត្ត មានយ៉ាងតិច ០២ ថ្ងៃ ក្នុងមួយសប្តាហ៍ នៅគណៈកម្មាធិការនិតិសម្បទា និងអភិវឌ្ឍន៍ ។

ក្រសួង និងស្ថាប័នដទៃទៀត នៃរាជរដ្ឋាភិបាល ក៏ត្រូវមានតំណាងចូលរួមក្នុងយន្តការ " ច្រកចេញ ចូលតែមួយ" នេះដែរ តែត្រូវចូលរួមតាមលក្ខណៈ " អែដហុក " ស្របតាមការអញ្ជើញរបស់អគ្គលេខាធិការ គ.ជ.នា ចំពោះតែកិច្ច ការងារណា ដែលពាក់ព័ន្ធទៅ នឹងសមត្ថកិច្ច នៃក្រសួង និងស្ថាប័នទាំងនោះ ។

មន្ត្រីទាំងនោះ គឺជាតំណាងពេញលេញរបស់ប្រធានស្ថាប័ន ស្ថិតរមួតក្នុងការទាក់ទងជាមួយប្រធានស្ថាប័នរបស់ខ្លួន ពិសេសខាងរបបរាយការណ៍ និងក្នុងការស្នើសុំយោបល់ពីប្រធានស្ថាប័នរបស់ខ្លួនហើយទទួលការប្រទានសិទ្ធិពេញលេញពីប្រធានស្ថាប័នរបស់ខ្លួន ក្នុងការបញ្ចេញយោបល់ និងក្នុងការសំរេច ការងារអ្វីមួយក្នុងក្របខ័ណ្ឌការងារនីតិសម្បទា និងអភិវឌ្ឍន៍ ។

លោកអគ្គលេខាធិការ " គ.ជ.នា " ត្រូវរៀបចំនិងប្រមូលផ្តុំនូវបណ្តាឯកសារចាំបាច់នានាអោយបានសព្វគ្រប់ហើយមានភាពច្បាស់លាស់ក្នុងការផ្តល់សំណុំឯកសារដែលត្រូវរួមគ្នាពិនិត្យ និងសំរេចក្នុងអង្គប្រជុំនៃស្ថាប័ន " ច្រកចេញ ចូលតែមួយ" ដល់មន្ត្រីជាតំណាងរបស់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ក្នុងរយៈពេលមួយសប្តាហ៍មុន ។ មន្ត្រីជាតំណាងរូបនោះ មានពេលវេលាគ្រប់គ្រាន់ សំរាប់ពិនិត្យពិចារណាឯកសារលើកមតិជូនប្រធានស្ថាប័ន និងសុំយោបល់ជាយថាហេតុ ពីប្រធានស្ថាប័ន សំរាប់ចូលរួមយោបល់ ក្នុងអង្គប្រជុំរបស់ស្ថាប័ន " ច្រកចេញ ចូលតែមួយ " ។ ទន្ទឹមនេះ លោកអគ្គលេខាធិការ គ.ជ.នា ត្រូវជំរាបលោកអគ្គលេខាធិការ ក.អ.ក ដើម្បីរៀបចំបញ្ចូលកម្មវិធី ឬ គំរោងនោះ ទៅក្នុងរបៀបវារៈ នៃអង្គប្រជុំរបស់ស្ថាប័ន " ច្រកចេញ ចូលតែមួយ " ។

សមាសភាពចូលរួមក្នុងអង្គប្រជុំ នៃស្ថាប័ន “ ច្រកចេញ ចូលតែមួយ ” ដើម្បីពិនិត្យ និងសំរេចរាល់គំរោងការ វិនិយោគ និង អភិវឌ្ឍន៍រួមមាន : គណៈកម្មាធិការប្រតិបត្តិការនៃ “ ក.អ.ក ” រួមមាន ៥ រូប ( ប្រធាន ក.អក អនុប្រធាន ក.អ.ក និងលោកអគ្គលេខាធិការទាំងបីរូប ) ព្រមទាំងតំណាងនៃក្រសួង និងស្ថាប័ននានាដែលមានការពាក់ព័ន្ធ ហើយដែលត្រូវបានប្រធានស្ថាប័នរបស់ខ្លួន ចាត់តាំងអោយមកបំពេញការងារអម ត.ជ.នា ក្នុងលក្ខណៈជាប្រចាំ ឬ ក្នុង លក្ខណៈ “ អែដហុក ” ។ កិច្ចប្រជុំរបស់ស្ថាប័ន “ ច្រកចេញ ចូលតែមួយ ” ត្រូវប្រព្រឹត្តិទៅនៅព្រឹកថ្ងៃអង្គារ រៀងរាល់ សប្តាហ៍ នៅទីស្តីការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា (វិមាន រដ្ឋាភិបាល ) ការប្រជុំត្រូវប្រព្រឹត្តិទៅក្រោមការដឹកនាំរបស់ ប្រធាន “ ក.អ.ក ” ។ ក្នុងករណីដែលប្រធានអវត្តមាន ឬ ជាប់រវល់ការកិច្ចផ្សេងៗ ឬ មានជំងឺមិនអាចចូលរួមប្រជុំបាន អនុប្រធាន ក.អ.ក ត្រូវដឹកនាំអង្គប្រជុំជំនួសប្រធាន ។ មន្ត្រីដែលជាតំណាងពេញលេញរបស់ប្រធានស្ថាប័នទាំងអស់ ទទួលការប្រទាន សិទ្ធិពេញលេញពីប្រធានស្ថាប័នរបស់ខ្លួន ក្នុងការបញ្ចេញយោបល់ និងក្នុងការសំរេចការងារអ្វីមួយ ក្នុង ក្របខ័ណ្ឌ ការងារវិនិយោគ និង អភិវឌ្ឍន៍ ។

នាយករដ្ឋមន្ត្រីទី១
ព្រះហស្តលេខានិងត្រា
**នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
**ហ៊ុន សែន**

***

# III- ការងារបណ្តាក្រសួង

## ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

## ប្រកាស

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤*

**ប្រកាសលេខ ៣៤៣៦ ប្រក.សក.ប**

**ស្តីពីការបង្កើតអនុគណៈកម្មការបច្ចេកទេសត្រួតពិនិត្យ**

**ការជួសជុលព្រលានយន្តហោះ ពោធិចិនតុង**

ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន